កាលបរិច្ឆេទៈ ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០១៨

# មេរៀនដាំដំណាំស្ពៃជើងទា

## ១.បច្ចេកទេសនៃការដាំស្ពៃជើងទា

### ១.១. ការរៀបចំដី

- ភ្ជួរដីហាលដីរយៈពេលពី៧-១០ថ្ងៃ (កុំដាំស្ពៃនៅលើដីដែលមានទឹកលិចនៅរដូវវស្សា)
- បន្ទាប់ពីនោះត្រូវប្រែដីយ៉ាងហោចណាស់២ទៅ៣ដងទៀត។

### ១.២. ការលើករង

☺ ការលើករងទទឹងយកប្រវែង១ម៉ែត្រ បណ្ដោយយកប្រវែង១០ម៉ែត្រឬអាស្រ័យតាមលទ្ធភាព នៅចន្លោះពីរងមួយទៅរងមួយត្រូវទុកចន្លោះពី២៥-៣០សង់ទីម៉ែត្រ។

☺ នៅរដូវវស្សាត្រូវលើករងកំពស់ពី២០-២៥ស.ម រាងខ្នងអណ្តើក។

☺ នៅរដូវប្រាំងត្រូវលើករងកំពស់ពី១០-១៥សង់ទីម៉ែត្រហើយរាងផតកណ្តាល។

រៀបចំដោយលោកភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)និង
លោក យុគ សឿង នាយករងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)

☺ ត្រូវដាក់ជីធម្មជាតិឬជីកំប៉ុស្តិ៍សម្រាប់ទ្រាប់បាតចំនួន៥-១០ គីឡូក្រាមក្នុង១ម៉ែត្រការ៉េ ហើយច្របល់វាឱ្យសព្វល្អជាមួយដីនៅក្នុងរង។

## ១.៣. ការជាំផុះ

- យកគ្រាប់ស្ពៃជើងទាមកហាលរយៈពេល៣០នាទី។
- យកគ្រាប់ស្ពៃនោះមកត្រាំទឹករយៈពេល៣ម៉ោង បន្ទាប់មកផ្អាប់វារយៈពេល១យប់ដើម្បីធ្វើឱ្យគ្រាប់ឆាប់រីក។

## 🕮 វិធីសាស្ត្រទី១៖

- រៀបចំថ្នាលឱ្យបានល្អ បន្ទាប់មកច្របល់គ្រាប់ស្ពៃជាមួយដីខ្សាច់ (ឧទាហរណ៍ៈ គ្រាប់ស្ពៃ០,១គីឡូក្រាមលាយជាមួយខ្សាច់០,៤គីឡូក្រាម)។
- រោយគ្រាប់ស្ពៃទៅក្នុងរងហើយស្រោចទឹកវាឱ្យជោគ ត្រូវស្រោចទឹកវា៣ដងក្នុង១ថ្ងៃ នៅពេលព្រឹក ពេលថ្ងៃ និងពេលល្ងាច។
- ត្រូវបាចផេះជុំវិញរងដើម្បីការពារសត្វស្រមោចពាំគ្រាប់។
- ពេលកូនស្ពៃអាយុបាន១៥-២០ថ្ងៃយើងអាចដកកូនទៅស្ទូងបាន
- មុនដកកូនស្ពៃយកទៅស្ទូងត្រូវផ្អាកស្រោចទឹករយៈពេល២ថ្ងៃ។
- ស្រោចទឹកវាឱ្យជោគ បន្ទាប់មកដកវាពីរងភ្លាម។
- ត្រូវដកកូនស្ពៃណាដែលល្អហើយមានទំហំប្រហាក់ប្រហែលគ្នា។

- ស្ទូងក្នុងចន្លោះពីគុម្ពមួយទៅគុម្ពមួយគឺប្រវែង១៥-២០ស.ម ហើយក្នុងចន្លោះរងពីមួយទៅមួយគឺប្រវែង២៥-៣០ស.ម។
- ត្រូវគ្របកូនស្ពៃដែលស្ទូងរួចរយៈពេលពី២-៣ថ្ងៃដើម្បីការពារកំដៅ
- ស្រោចទឹកស្ពៃនៅពេលព្រឹកនិងពេលល្ងាចរហូតដល់ពេលប្រមូលផល។

### 🕮 វិធីសាស្ត្រទី២៖

- ធ្វើរងឱ្យបានល្អបន្ទាប់មកយកគ្រាប់ស្ពៃដែលបានផ្លាប់រួចមកលាយជាមួយដីខ្សាច់៤ភាគហើយច្របល់ឱ្យសព្វ។
- ព្រោះគ្រាប់ស្ពៃក្នុងថ្នាលរួចហើយស្រោចទឹកវា ឬធ្វើជាចង្អូរ ដោយយកទទឹងរងដូចរងត្រកួនដែរ។ គម្លាតចង្អូរគឺប្រវែងពី១៥-២០ស.ម បន្ទាប់មកយកគ្រាប់ស្ពៃរោយទៅក្នុងចង្អូររួចស្រោចទឹកវា។

## ២.ការថែទាំ

- ☺ ត្រូវស្រោចទឹក១ថ្ងៃ២ដងគឺនៅពេលព្រឹកនិងពេលល្ងាច។
- ☺ បោចស្មៅនិងដាក់ជី។
- ☺ ឃ្លាំមើលសត្វល្អិតជាប្រចាំ។

## ៣.ការប្រមូលផល

✓ នៅពេលស្ពៃអាយុបាន៤៥-៥០ថ្ងៃ យើងអាចប្រមូលផលបានចំពោះស្ពៃដែលគេសាបកូនដោយផ្ទាល់។ រីឯស្ពៃដែលគេដកកូនស្ទូងគឺមានអាយុពី៥០-៦០ថ្ងៃ ទើបអាចប្រមូលផលបាន។

✓ ទិន្នផលដែលយើងទទួលបានពី១៦-១៨តោនក្នុង១ហិកតា ប៉ុន្តែវាក៏អាស្រ័យលើការថែទាំនិងគ្រាប់ពូជស្ពៃផងដែរ៕

**សូមអរគុណ**

រៀបចំដោយលោកគួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)និង
លោក យុគ សឿង នាយករងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)

# មេរៀនដំណាំត្រកួនស

## ១.ប្រវត្តិសង្ខេបនៃការដាំត្រកួនស

ដំណាំត្រកួនគឺជាដំណាំដែលងាយស្រួលដាំជាងគេបំផុតហើយវាជាប្រភេទដំណាំឆ្លងកាត់ផងដែរ។

នៅពេលដំណាំត្រកួនមានអាយុបានប្រហែលជា២២-២៥ថ្ងៃ យើងអាចប្រមូលផលបានដោយចាប់រាប់ពីថ្ងៃដាំដំបូងឬសាបដំបូង។ បន្ថែមពីនោះ យើងក៏អាចយកដំណាំនេះមកធ្វើជាបន្លែសម្រាប់បរិភោគជាញឹកញាប់ឬសម្រាប់លក់ដូរក៏បានហើយទទួលបានប្រាក់ចំណូលយ៉ាងងាយ។ ចំណុចពិសេសមួយទៀតដំណាំត្រកួន ដាំមិនរើសរដូវកាលឡើយ។

ដំណាំត្រកួននេះត្រូវការកំដៅពី៨០-១០០ភាគរយដើម្បីទ្រទ្រង់ដើមរបស់វា ហើយវាក៏ត្រូវការទឹកនិងសំណើមត្រជាក់ជាអចិន្ត្រៃយ៍ផងដែរ បន្ទាប់មកវានឹងធ្វើឱ្យដំណាំនេះឆាប់លូតលាស់បានល្អនិងឆាប់ទទួលផល។

## ២.គម្រោងនៃការដាំត្រកួនស

ដើម្បីដាំត្រកួនសយើងត្រូវមានគម្រោងដាំដូចខាងក្រោម៖

រៀបចំដោយលោកភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)និង
លោក យុគ សឿង នាយករងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)

១. ជាដំបូងត្រូវជ្រើសរើសទីតាំងសម្រាប់ដាំ

២. កាប់ ឬភ្ជួររាស់ដីនិងហាលដីប្រហែល១សប្តាហ៍

៣. មានប្រភពទឹកសម្រាប់ប្រើប្រាស់

៤. មានគ្រាប់ពូជសម្រាប់ដាំ

៥. មានជីធម្មជាតិសម្រាប់ប្រើប្រាស់

៦. មានឧបករណ៍ពាក់ព័ន្ធដូចជា ចបកាប់ ចបជីក ឡាំងស្រោច បង្គីនិងកម្លាំងអូសទាញ។ល។

៧. ចំណុចសំខាន់មួយទៀតគឺកម្លាំងសម្រាប់ថែទាំនិងបច្ចេកទេស។

## ៣.បច្ចេកទេសនៃការដាំត្រកួនស

ដើម្បីដាំត្រកួនសយើងត្រូវមានបច្ចេកទេសដាំដូចខាងក្រោមៈ

១. ជាដំបូង លើករងដាំបន្ទាប់ពីកាប់ឬភ្ជួររាស់ដី

២. ច្របល់ជីធម្មជាតិជាមួយនឹងដីរងឱ្យបានសព្វ

៣. ធ្វើចង្អូរកាត់ជួរទទឹងរង

៤. ខ្ចប់គ្រាប់ពូជជាមួយក្រណាត់ហើយត្រាំទឹកធុងរយៈពេល១យប់

៥. បន្ទាប់ពីត្រាំទឹក១យប់ យកគ្រាប់ពូជនោះទៅដាំ

៦. ស្រោចទឹក១ថ្ងៃ២ដងគឺនៅពេលព្រឹកនិងពេលល្ងាច

៧. ត្រូវថែទាំវាជាប្រចាំ។

---

រៀបចំដោយលោកភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)និង
លោក យុគ សឿង នាយករងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)

## 🕮 ចំណាំសម្រាប់ចំណាចសំខាន់នៃទំហំរងត្រកួន

- ទទឹងរងយកប្រវែង១ម៉ែត្រ
- បណ្តោយរងយកប្រវែង៥ទៅ១០ម៉ែត្រ
- កំពស់រងយកប្រវែង១០សង់ទីម៉ែត្រ
- ទ្រូងរងនីមួយៗ(ផ្លូវដើរ) នៅចន្លោះពីរងមួយទៅរងមួយយកប្រវែង ៤០សង់ទីម៉ែត្រ ឬ៤តឹក។

**សូមអរគុណ**

រៀបចំដោយលោកភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)និង
លោក យុគ សឿង នាយករងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)